**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩

ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ៖ ៩៦០/២២ (គ.វ.ក-១៩)

ថ្ងៃ...អង្គារ ១៤កើត...ខែ...អាសាឍ... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី...២៨...ខែ...មិថុនា...ឆ្នាំ ២០២២

**រដ្ឋលេខាធិការក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធាន**

**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជាពិសេសដូសទី៣ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។

**យោង** ៖-សារសម្លេងរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាល្ងាចថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២។

-ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ លើលិខិតលេខ ៩៥៩/២២ គ.វ.ក-១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីអំពីស្ថានភាពនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជាពិសេសដូសទី៣ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ **គ.វ.ក-១៩** សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត** មេត្តាជ្រាបថា ដើម្បីពន្លឿនការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជាពិសេសដូសទី៣ បន្ថែមទៀត សំដៅបញ្ចៀសនូវការវាយលុកសារជាថ្មី នៃវីរុសកូវីដ-១៩ ជាពិសេសពពួកបម្លែងថ្មីៗ និងបង្ការនូវភាពធ្ងន់ធ្ងរ ព្រមទាំងការស្លាប់ដែលបង្កឡើងដោយវីរុសកូវីដ-១៩ និងដោយមានការយល់ព្រមដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី គ.វ.ក-១៩** សូម៖

- ប្រគល់ភារកិច្ចជូន ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ដែលជាប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត ទទួលខុសត្រូវ បន្តយកចិត្តទុកដាក់ខ្ពស់ និងចាត់ចែងជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមស្រុក/ក្រុង/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយធ្វើការកៀរគរប្រជាពលរដ្ឋតាមភូមិ ឃុំនីមួយៗ និងចាត់ចែងពង្រាយក្រុមគ្រូពេទ្យចុះចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមភូមិ ឃុំ ជូនប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នា។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- រដ្ឋបាលរាជធានី-ខេត្ត ត្រូវបន្តពិនិត្យ តាមដាន ជំរុញ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រជាជនដែលបានចាក់ និងមិនបានចាក់វ៉ាក់សាំងដូសទី៣ (ជាប្រភេទណា កម្មករ កសិករ ឬក្រុមណា) នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានជាក់លាក់ រួចផ្ញើមក គ.វ.ក-១៩ យ៉ាងយូរត្រឹមថ្ងៃសុក្រទី១៥ ខែកក្កដា ឆ្នាំ២០២២។
- រដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំចាត់ចែងធ្វើផែនការចាក់វ៉ាក់សាំងកូវីដ-១៩ ដោយផ្អែកលើចំនួនដែលបានធ្វើបច្ចុប្បន្នភាព ជាក់ស្តែងរួច ដើម្បីចាត់ចែងការចុះចាក់ផ្ទាល់ដល់ទីតាំងកំណត់ជាក់លាក់ ដោយពង្រាយក្រុមគ្រូពេទ្យដល់ភូមិ ឃុំ រួមទាំង ជំរុញការផ្តល់សេវាចាក់វ៉ាក់សាំងនេះទាំងថ្ងៃសៅរ៍, ថ្ងៃអាទិត្យ និងថ្ងៃបុណ្យនានា។
- រដ្ឋបាលរាជធានី-ខេត្ត បន្តការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមគោលដៅសំខាន់ៗមានដូចជារោងចក្រ-សហគ្រាស សាលារៀន និងក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ផ្សារ កម្មករសំណង់ អ្នកបម្រើតាមភោជនីយដ្ឋាន សណ្ឋាគារ កន្លែងកម្សាន្តសប្បាយ កន្លែងស្នាក់នៅ និងកន្លែងធ្វើការប្រមូលផ្តុំ ។ល។) ដោយជំរុញឱ្យមានកិច្ចសហការពីម្ចាស់ទីតាំងទាំងនេះ។
- បន្តអប់រំប្រជាជននៅតាមមូលដ្ឋានឱ្យយល់ដឹងពីសារៈសំខាន់នៃការមកទទួលយកការចាក់វ៉ាក់សាំងដូសជំរុញទី៣ ទី៤ និងទី៥ ដើម្បីជំរុញការងារចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យមានកំណើនឡើង បន្តរក្សាភាពស៊ាំរបស់បុគ្គល និងភាពស៊ាំរបស់សហគមន៍បានរឹងមាំ ជានានិរន្តរភាពនៃការបើកដំណើរការសេដ្ឋកិច្ច និងសង្គមជាតិក្នុងការរស់នៅធម្មតាតាមបែបប្រក្រតីភាពថ្មី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីនាងខ្ញុំ។

**វេជ្ជ. ឱ វណ្ណឌីន**

**<u>ចម្លងជូន៖</u>**
- មន្ទីរសុខាភិបាលរាជធានី ខេត្តទាំង២៥
- ឯកសារ-កាលប្បវត្តិ



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩